**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការខេត្តកំពង់ធំ**

<u>សាលក្រម</u>

លេខ ៥២ ក ចុះថ្ងៃទី ០៩

ខែ ធ្នូ ឆ្នាំ ២០០៤

<u>សំណុំរឿង</u>

លេខ ១១៦ ចុះថ្ងៃទី ០៣

ខែ កញ្ញា ឆ្នាំ ២០០៤

**តាមនាមប្រជារាស្ត្រខ្មែរ**

តុលាការខេត្តកំពង់ធំ បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាព របស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅទីតុលាការខេត្តកំពង់ធំ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ:

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted]

**<u>តំណាងអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

*សាលក្រមនេះចូលស្ថានពរចាប់តាំងពីថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៥ តទៅ*
*ដោយគូក្តីមិនចូលតវ៉ាតាមកំណត់ច្បាប់ ។*
*កំពង់ធំ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥*
***ប្រធានតុលាការខេត្ត***

[redacted]

ដើម្បីជំនុំជំរះរឿងក្តីរដ្ឋប្បវេណីលេខ ១១៦ ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៤ ដែលមានកម្មវត្ថុបណ្តឹង ប្តឹងទាមទារប្រាក់ចំនួន **១.០០០ដុល្លា ការប្រាក់ ៥០ដុល្លាក្នុងមួយខែ និង ជម្ងឺចិត្ត ២០០ដុល្លា** ។

-រវាងដើមចោទ **ស មស** ភេទប្រុស អាយុ ៣៩ឆ្នាំ របររកស៊ីធ្វើចំការ នៅភូមិរំចេក ឃុំទ្រៀល ស្រុកបារាយ ខេត្តកំពង់ធំ ឪពុកឈ្មោះ **យ គ** (រ) ម្តាយ ឈ្មោះ **ល ឆ** (រ) ប្រពន្ធឈ្មោះ **ខ សណ** មានកូន ០៣នាក់ ។

-និង ចុងចម្លើយឈ្មោះ **ឆ សះ** ភេទស្រី អាយុ ៣៩ឆ្នាំ របររកស៊ីលក់ដូរនៅ ភូមិថ្មី ឃុំទ្រៀល ស្រុកបារាយណ៍ ខេត្តកំពង់ធំ ឪពុកឈ្មោះ **ឆ ស** ៉ស៉ ម្តាយឈ្មោះ **ឯ ស** ៉ស៉ ប្តីឈ្មោះ **ស សម** មានកូន ០៤នាក់ ។

**<u>ឯរឿងហេតុមានដូចតទៅ</u>**

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០១ របស់ដើមចោទឈ្មោះ **ស មស** បានប្តឹងទាមទារ ប្រាក់ពីឈ្មោះ **ឆ សះ** ដោយសំអាងហេតុថា កាលពីថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ វេលាម៉ោងប្រហែល ០៣រសៀល ឈ្មោះ **ឆ សះ** បានខ្ចីចង ការប្រាក់ពីខ្លួនចំនួន ១.០០០ដុល្លាគិតការប្រាក់ ៥០ដុល្លាក្នុងមួយខែ ដោយបានធ្វើកិច្ចសន្យា ដាក់បញ្ចាំប្លង់ដីទំហំ ១០មx៨០ម ហើយសន្យាសងទាំងប្រាក់ដើម និង ការប្រាក់នៅ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០០ ។ តែចាប់ពីពេលខ្ចីទៅចុងចម្លើយសងបាន ៦០០ដុល្លា ស្មើ ០៨ខែនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០០ ឈប់សងរហូតសព្វថ្ងៃ ។ សំណូមពរ

CamScanner

តុលាការទាមទារជម្ងឺចិត្ត ២០០ដុល្លា និង ការប្រាក់អោយគ្រប់ចំនួនទើបសុខចិត្ត ។ បើចុងចម្លើយមិនព្រមសងសុំតុលាការរឹបអូសទ្រព្យសម្បត្តិដែលដាក់បញ្ចាំលក់ឡាយឡុងតាមកិច្ចសន្យា ពិ ទ្រព្យសម្បត្តិដែលចុងចម្លើយបានលក់ឡាយឡុង ្របើនៅតែសងមិនគ្រប់ហើយរឹងទទឹងសុំតុលាការដាក់គុកបង្ខំរូបកាយ ដើម្បីទាមទារប្រាក់ដែលជំពាក់នេះ ។

-បានឃើញរបាយការណ៍ជូនរឿងទៅជំនុំជំរះលេខ ៦៩៣ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៤ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ៦៩៤ ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៤ ។

## នាពេលសវនាការ

-ដើមចោទឈ្មោះ ស មស ឆ្លើយថា ខ្លួនប្តឹងទាមទារប្រាក់ឈ្មោះ ឆ សរ ដោយមូលហេតុថា កាលពីថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៩៩ ឈ្មោះ ឆ សរ និង ឈ្មោះ ស សម បានទៅចងការប្រាក់ពីខ្លួនចំនួន ១.០០០ដុល្លា គិតការប្រាក់អោយខ្លួន ០៥ភាគរយក្នុងមួយខែស្មើ ៥០ដុល្លាលើប្រាក់ដើម ១.០០០ដុល្លា ដោយធ្វើកិច្ចសន្យាមានរដ្ឋអំណាចទទួលស្គាល់ត្រឹមត្រូវតាមច្បាប់ ព្រមទាំងមានដាក់បញ្ចាំដីលំនៅដ្ឋានមានបង្កាន់ដៃលេខ ១៤២៧ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ អោយផង ។ ចាប់តាំងពីពេលខ្ចីទៅសងបានប្រាក់ ១០០ដុល្លា ហើយឈប់សងរហូតដល់សព្វថ្ងៃដោយបានគេចខ្លួនបាត់ពីទីលំនៅ ទើបខ្លួនប្តឹងទាមទារមកតុលាការនេះ ។ សំណូមពរតុលាការ គឺទាមទារប្រាក់ដើម ១.០០០ដុល្លា ការប្រាក់ ៥០ដុល្លាក្នុងមួយខែ គិតពីថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០០ រហូតសងប្រាក់ដើមគ្រប់ចំនួន និង ទាមទារប្រាក់ជម្ងឺចិត្តចំនួន ៥០០ដុល្លា ។ ករណីឈ្មោះ ឆ សរ គ្មានប្រាក់សងទេ សុំតុលាការរឹបអូសទ្រព្យសម្បត្តិដាក់បញ្ចាំលក់ឡាយឡុង បើរឹងទទឹងសុំអោយដាក់គុកបង្ខំរូបកាយដើម្បីទារប្រាក់បំណុល ។

-តំណាងចុងចម្លើយឈ្មោះ ង ចរ និង ឈ្មោះ ឆ សរ ឆ្លើយថា កាលពីថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ឈ្មោះ ឆ សរ ត្រូវជាប្អូនថ្លៃខ្លួនបានខ្ចីចងការប្រាក់ពីឈ្មោះ ស មស ចំនួន ១.០០០ដុល្លាមានធ្វើលិខិតស្នាម ។ បន្ទាប់ពីខ្ចីប្រាក់ចំនួន ១.០០០ដុល្លាពីឈ្មោះ ស មស ឈ្មោះ ឆ សរ បានខ្ចីប្រាក់ខ្លួន ៥០០ដុល្លាសងថ្លៃការប្រាក់រហូតដល់ឆ្នាំ ២០០០ ពុំបានប្រាក់សងដើមចោទ ទើបរត់ទៅរកស៊ីនៅអន្លង់វែងរហូតសព្វថ្ងៃនេះ ។ ចំពោះការប្តឹងទាមទារសុំរបស់ដើមចោទពីឈ្មោះ ឆ សរ ជាប្អូនថ្លៃខ្លួននេះ គឺខ្លួនជាមួយប្រពន្ធសុំសងអោយជំនួសចំនួន ១.០០០ដុល្លា ហើយសុំអោយដើមចោទបញ្ចប់រឿងចាប់ពីពេលនេះតទៅ ។

## តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា :

រឿងក្តីនេះសុំតុលាការសំរេចតាមច្បាប់ ។

-ក្រោយពីបានស្តាប់ដើមចោទឆ្លើយអោយការណ៍ និង ប្តឹងសុំ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់ចុងចម្លើយ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តកំពង់ធំ

-យល់ឃើញថា ពាក្យបណ្តឹងចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០១ របស់ដើមចោទឈ្មោះ ស មស មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

CS CamScanner

-យល់ឃើញថា លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៤ របស់ឈ្មោះ **ឆ សរ** ឱ្យទៅឈ្មោះ **ង ចរ** និង ឈ្មោះ **ឆ សរ** ជាតំណាងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-យល់ឃើញថា ចុងចម្លើយឈ្មោះ **ឆ សរ** និង ជាតំណាងរបស់ខ្លួនឈ្មោះ **ង ចរ** បានស្ម័គ្រចិត្តសងប្រាក់ជំពាក់ឱ្យទៅដើមចោទ ដោយចោទឈ្មោះ **ស មស** បានទទួលប្រាក់ ១.០០០ដុល្លាអាមេរិកតាមកំណត់ហេតុប្រគល់ប្រាក់ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៤ រួចហើយនោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-យល់ឃើញថា ពាក្យបណ្ដឹងចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៤ របស់ដើមចោទឈ្មោះ **ស មស** សុំឈប់ប្ដឹងមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

## ហេតុដូច្នេះតុលាការខេត្តកំពង់ធំ
## វិនិច្ឆ័យសេចក្ដី

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០១ របស់ដើមចោទឈ្មោះ **ស មហ** ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ទទួលលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៤ របស់ឈ្មោះ **ឆ សរ** ឱ្យទៅឈ្មោះ **ង ចរ** និង ឈ្មោះ **ឆ សរ** ជាតំណាងទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៤ របស់ដើមចោទឈ្មោះ **ស មស** សុំឈប់ប្ដឹងពីឈ្មោះ **ឆ សរ** តទៅទៀត ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤-ចំណាយសំណុំរឿងរដ្ឋប្បវេណីលេខ ១១៦ ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៤ របស់តុលាការខេត្តកំពង់ធំ ចេញពីបញ្ជីក្ដី ។

៥-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន ៧.០០០៛០០ ដែលដើមចោទបានបង់រួចហើយ គឺពន្ធចុះបញ្ជីក្ដី ពន្ធហ្វឹង ១.៨០០៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛០០ រង្វាន់ប្រគល់ដីកាកោះ ៥.០០០៛០០ ។

៦-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈកំបាំងមុខគូក្ដី ទុកសិទ្ធិប្ដឹងទាស់ និង ប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជំរះ**
**ហត្ថលេខា និង ត្រា**
[redacted]

CS CamScanner